# ប្រយោជន៍នៃព្រះពុទ្ធសាសនា

## ព្រះមុនីកោសល សូរ ហាយ រៀបរៀង

សាសនាទាំងអស់ក្នុងសកលលោកសុទ្ធតែមានបញ្ញត្តិ មានទ្រឹស្តី មានអត្ថបទ សម្រាប់ពន្យល់ដឹកនាំប្រដៅមនុស្ស ដើម្បីប្រយោជន៍ឱ្យគ្រាន់តែមនុស្សជឿជាប់ចិត្តបាក់ផ្គត់ ទៅជាទំនៀមទម្លាប់ដោយឥតហេតុផលក៏មាន ប្រដៅមនុស្សឱ្យមានសីលធម៌ក៏មាន ប៉ុន្តែក្នុងទីនេះ យើងអ្នកនិពន្ធមិនមានបំណងអធិប្បាយអំពីប្រយោជន៍របស់សាសនាដទៃទេ សូមអធិប្បាយចំពោះតែប្រយោជន៍នៃព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជាយើងប៉ុណ្ណោះ ដូចសេចក្តីតទៅនេះ ៖

វិជ្ជានៃពុទ្ធសាសនា ជាវិជ្ជាដែលមានគុណភាពមានតម្លៃ គួរអ្នកសិក្សាចំណាយពេលវេលា ដើម្បីសិក្សាគម្ពីរព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋខ្មែរយើងឱ្យយល់គោលបំណងរបស់ព្រះពុទ្ធនិងលោកអ្នកប្រាជ្ញក្នុងសម័យជាន់មុនផង ដើម្បីស្គាល់ច្បាស់នូវប្រយោជន៍របស់សាសនាក្នុងបច្ចុប្បន្ននិងបរលោកផង ព្រោះថាសាសនាទាំងអស់ សុទ្ធតែមានទ្រឹស្តីសម្រាប់ប្រៀនប្រដៅមនុស្ស ឱ្យចុះចូលជឿតាមឱវាទរបស់គ្រូអ្នកប្រៀនប្រដៅ។ សាសនាខ្លះពុំសូវមានប្រយោជន៍ ប៉ុន្តែទុកជាយ៉ាងណាក៏ដោយយើងគួរតែសិក្សាឱ្យស្គាល់មូលហេតុនៃសាសនានោះៗ ដើម្បីជាគ្រឿងស្ទាបស្ទង់ប្តូរយោបល់អំពីសាសនា សម្រាប់លាតត្រដាង ទុកជាមេគំនិតក្នុងការពិចារណាមើលឱ្យកើតសតិបញ្ញាបរិបូណ៌ សម្រាប់ឋានៈនៃខ្លួនយើងជាបុរស-ស្ត្រីអ្នកសិក្សា។ យើងអ្នកសិក្សា ដោយការមើលសាសនាច្រើន ដោយការពិនិត្យពិចារណាច្រើន អាចឃើញប្រយោជន៍នៃព្រះពុទ្ធសាសនាច្រើនយ៉ាង ប៉ុន្តែក្នុងទីនេះ សូមអធិប្បាយដោយសង្ខេបតាមយោបល់ ដូចដំណើរសេចក្តីដែលត្រូវវែកញែកតទៅនេះ ៖

១–ព្រះពុទ្ធសាសនាជាផ្លូវនៃសន្តិភាព ព្រះពុទ្ធសាសនាសម្បូណ៌ទៅដោយសីលធម៌និងប្រពៃណីដ៏ល្អ ដែលគួរប្រតិបត្តិតាម ជាផ្លូវដើម្បីឱ្យកើតប្រាជ្ញាភ្លឺថ្លាឃើញធម៌រំលត់ទុក្ខនាំសេចក្តីសុខមកឱ្យដល់មនុស្សអ្នកប្រតិបត្តិ ទុកដូចជាដួងប្រទីបមួយដ៏ធំក្នុងលោក សម្រាប់ទ្រោលបំភ្លឺមនុស្សលោកឱ្យឃើញផ្លូវប្រតិបត្តិ ដើរកាត់តម្រង់ទៅរកសន្តិសុខទាំងក្នុងបច្ចុប្បន្ននិងបរលោក ជាសាសនាលូកវាវរកឃើញឫសគល់កិលេសមានលោភៈជាដើម ឃើញមគ្គផលនិព្វានបាន។ ព្រះពុទ្ធសាសនាមានគុណភាពប្រកបដោយប្រយោជន៍ជាច្រើនយ៉ាង ដូចយ៉ាងការរីកចម្រើនឈានលឿនទៅមុខរបស់មនុស្សលោក ក៏ច្រើនតែកើតមកអំពីព្រះពុទ្ធ

សាសនាជាអ្នកចង្អុលប្រាប់ជាដំបូង សូម្បីវេជ្ជសាស្ត្រនិងវិទ្យាសាស្ត្រ ដែលរាប់ថាជាវិជ្ជាសម័យថ្មី ក៏ច្រើនតែកើតមកអំពីទ្រឹស្តីព្រះពុទ្ធសាសនា ដែលអ្នកប្រាជ្ញចម្លងផ្គិតយករបៀបទុកជាមេគំនិត។

សម្រាប់ប្រទេសទាំងអស់ច្រើនតែទទួលដឹងថា សេចក្តីចម្រើនក្នុងសិល្បវិទ្យានិងសន្តិភាពនៃសង្គមមនុស្ស បានទទួលកំណើតអំពីព្រះពុទ្ធសាសនាដោយពិត។ អ្នកប្រាជ្ញប្រវត្តិសាស្ត្រប្រទេសជប៉ុន បានសរសេរចុះក្នុងប្រវត្តិសាស្ត្រថា **"ព្រះពុទ្ធសាសនា ជាសាសនានាំសេចក្តីចម្រើនមកប្រគល់ឱ្យប្រទេសជប៉ុន ព្រះពុទ្ធសាសនាបានបើកទ្វារប្រទេសជប៉ុនដោយទ្រឹស្តីមុនដំបូងបង្អស់ ឱ្យប្រទេសជប៉ុនទទួលសន្តិភាពឈមមុខទៅរកសេចក្តីចម្រើន មានកិត្តិស័ព្ទមុនគេក្នុងចំណោមជាតិស្បែកខ្មៅ ព្រោះហេតុនោះ យើងជាជាតិជប៉ុន នៅចុងបូព៌ាប្រទេស គួរណាស់តែសើរើសិក្សាអនុវត្តព្រះពុទ្ធសាសនាដោយគោរពមិនសូវធ្វេសប្រហែស"**។ បើជាមនុស្សក្នុងសកលលោកព្រមព្រៀងគ្នាកាន់ព្រះពុទ្ធសាសនាឱ្យត្រឹមត្រូវជិតដល់គ្រប់គ្នាទាំងអស់ ប្រាកដជាបានសន្តិភាពដោយពិតពុំខាន។

២–ព្រះពុទ្ធសាសនាជាឃ្លាំងនៃការសិក្សា ការសិក្សា ព្រះពុទ្ធសាសនាគ្មានបំណងខាងសម្ភារនិយម ដូចវិជ្ជាបច្ចេកទេសក្នុងផ្លូវលោក ដែលទាក់ទងដោយគ្រឿងសស្ត្រាវុធទេ គឺមានគោលដៅចំពោះតែខាងចិត្តនិយម។ ប្រទេសកម្ពុជារបស់យើង ដែលបានទទួលគម្ពីរច្បាប់ព្រះពុទ្ធសាសនាមកសិក្សាឱ្យមានការចេះដឹងក្នុងផ្លូវលទ្ធិសាសនាក្តី ក្នុងផ្លូវអក្សរសាស្ត្រក្តី ច្រើនតែកើតអំពីវត្តអារាមរបស់ព្រះពុទ្ធសាសនាជាដំបូង ឃើញថាការសិក្សារបស់ខ្មែរឋិតនៅក្នុងឃ្លាំងគឺព្រះពុទ្ធសាសនាជាច្រើនណាស់ សូម្បីវិជ្ជាពេទ្យក៏ច្រើនតែកើតមកអំពីបព្វជិតពុទ្ធសាសនាដែរ ទោះបីមានវិន័យហាមមិនឱ្យបព្វជិតធ្វើពេទ្យមើលជំងឺ ក៏ហាមបានដោយក្រណាស់ ដោយហេតុបព្វជិតមើលជំងឺឱ្យទទេៗមិនបាច់យកថ្លៃ។

៣–វត្តអារាមជាសភានៃមហាជន ការប្រជុំគ្នាដើម្បីសន្ទនាពីធម៌អាថ៌ឬពីព្រឹត្តិការណ៍ណាមួយ តាមសេចក្តីចេះដឹងក្នុងសម័យនិយមនោះៗ ក៏ត្រូវតែធ្វើក្នុងវត្តអារាម។ មួយទៀត វត្តអារាមទុកជារោងហត្ថកម្មរបស់ការជាង មានការជាងឈើ ការកសាងសាលា វិហារជាដើម។ ប្រភពនៃសេចក្តីចម្រើនរបស់ប្រទេសយើង ដែលមានឈ្មោះជាប់មកថា ជាប្រទេសមានអក្សរសាស្ត្រ មានបុរាណវត្ថុជាកេរដំណែល មានប្រជាជាតិជាម្ចាស់ប្រទេស មានព្រះមហាក្សត្រសោយរាជ្យ ក៏ដោយអំណាចគុណនៃព្រះពុទ្ធសាសនា ឬថាព្រះពុទ្ធសាសនាទុកជាមន្ទីរសម្រាប់តាំងទុកឯកសារប្រជុំវប្បធម៌ខាងផ្នែកអក្សរសាស្ត្រ ប្រវត្តិសាស្ត្រ

និងសិល្បហត្ថកម្មជាដើមរបស់ជាតិ ឱ្យជាតិមានជីវិតរស់នៅរហូតមក រួមសេចក្ដីថា "ព្រះពុទ្ធសាសនាមានវត្តនេះហើយ ជាទីមហាសន្និបាតរបស់អ្នកស្រុក"។

៤–វត្តអារាមជាសាលារៀន យើងបានឃើញជាក់ច្បាស់ហើយថា វត្តអារាមកាលដែលប្រទេសយើង មិនទាន់មានសាលារៀនអក្សរសាស្ត្រខាងក្រៅវត្តតាមផ្លូវការនៅឡើយ មានតែវត្តអារាមហ្នឹងឯងជាសាលារៀន កាលដែលមិនទាន់មានមន្ទីរពេទ្យព្យាបាលរោគ មានតែវត្តអារាមជាមន្ទីរពេទ្យសម្រាប់មើលជំងឺនៃមហាជន មិនត្រឹមតែមើលជំងឺក្នុងកាយប៉ុណ្ណោះទេ គឺមើលជំងឺក្នុងផ្លូវចិត្តថែមទៀត ព្រោះថា ការកើតទុក្ខព្រួយបារម្ភក្នុងផ្លូវចិត្តនេះចាត់ជារោគមួយយ៉ាងចំណាស់ វត្តអារាមនៃពុទ្ធសាសនាឈ្មោះថាជាកន្លែងសម្រាប់រម្ងាប់រោគកាយ-ចិត្តរបស់ពុទ្ធបរិស័ទដើងវត្តដែលមានទុក្ខឱ្យធូរស្រាល ឱ្យជាសះស្បើយទៅ។

៥–វត្តអារាមជាកន្លែងអាហារូបករណ៍ រាជធានីភ្នំពេញមានវត្តឧណ្ណាលោម វត្តលង្កា វត្តបទុមវតីជាដើម ជាវត្តទទួលបន្ទុកនៃពួកភិក្ខុ-សាមណេរនិងក្មេងតូចធំបានច្រើនណាស់។ វត្តនីមួយៗមានភិក្ខុ-សាមណេរនិងក្មេងដែលចេញស្វះពន្លះអំពីស្រុក-ខេត្តផ្សេងៗមកសម្នាក់អាស្រ័យនៅដើម្បីសិក្សារៀនសូត្រយកចំណេះវិជ្ជា ព្រោះថា ក្រុងភ្នំពេញជាទីប្រជុំធំនៃវិជ្ជា សម្បូណ៌ដោយការសិក្សាជាងទីឯទៀត។ ពួកភិក្ខុដែលមកនៅក្នុងវត្តទាំងនោះបានយូរឆ្នាំ ទាំងមានសមត្ថភាពគ្រាន់បើ ហើយបានធ្វើជាមេកុដិ មេក្រុមនៃវត្តនីមួយៗ អាចទទួលចិញ្ចឹមភិក្ខុ-សាមណេរនិងក្មេងឱ្យនៅរៀនសូត្រ ទាល់តែសម្រេចអាចទទួលលទ្ធផលនៃការសិក្សាបាន។ ពួកក្មេងដែលមកនៅអាស្រ័យជ្រកកោនក្នុងវត្តជាមួយនឹងព្រះសង្ឃនោះសុទ្ធតែជាកូនអ្នកស្រែចម្ការក្រទ័លទ្រព្យសម្បត្តិ។ គួរឱ្យអាណោចអាធ័ម អាណិតអាសូរពួកក្មេងកម្សត់ទាំងនេះពន់ពេក បើកុំតែមានវត្តព្រះពុទ្ធសាសនាជាកន្លែងអាហារូបករណ៍ ប្រហែលជាក្មេងកម្សត់ទាំងនោះមិនបានទទួលរស្មីនៃការសិក្សាដូចកូនអ្នកមានទ្រព្យទេ ប្រែសេចក្ដីឱ្យច្បាស់ថា "កូនអ្នកក្រីក្ររស់នៅដោយសារបាយវត្ត" ខំទ្រាំទ្រនៅបំពេញការសិក្សាទាំងរហេមរហាមទាល់តែសម្រេចផលនៃការសិក្សា អាចឡើងឋានៈទៅជាអ្នកមានជីវភាពខ្ពង់ខ្ពស់ តាមសមគួរដល់សមត្ថភាពរបស់ខ្លួនបាន។ ចំណែកខាងកូនរបស់អស់លោកឥស្សរជនឬគហបតី គេមិនបាច់ត្រូវការឱ្យមកជ្រកកោននៅអាស្រ័យក្នុងវត្តឡើយ។

កូនចៅរបស់អ្នកក្រីក្រ បានទទួលសេចក្ដីសង្គ្រោះអំពីបព្វជិតពុទ្ធសាសនិកក្នុងឆ្នាំនីមួយៗបានច្រើនអ្នកណាស់ ដូចយ៉ាងវត្តធំៗ មានក្មេងពីចំនួន៣០០ដល់៤០០នាក់។ ចំនួនពួកក្មេងទាំងប៉ុណ្ណោះ បើជារដ្ឋាភិបាលទទួលយកទៅចិញ្ចឹមនោះ ខាតបង់ថវិកាជាតិមិនមែន

តិចទេក្នុងមួយឆ្នាំៗ។ ក្មេងទាំងនេះឈ្មោះថារស់នៅដោយអាស្រ័យនឹងម្លប់ព្រះពុទ្ធសាសនា នៅជ្រកកោនក្រោមទង់ជ័យនៃព្រះពុទ្ធសាសនាហើយតស៊ូខំប្រឹងសិក្សា ទាល់តែបានលទ្ធផលនៃការសិក្សារបស់ខ្លួន។ ក្នុងករណីនេះឃើញថា ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាយើងមានប្រយោជន៍ធំទូលាយអាចជួយសង្គ្រោះទំនុកបម្រុងដល់ប្រទេសជាតិបាន គឺថាព្រះពុទ្ធសាសនាទុកដូចជាកន្លែងអាហារូបករណ៍មួយដ៏ប្រសើរ របស់ពួកក្មេងអ្នកក្រីក្រ អាចចិញ្ចឹមជីវិតមនុស្សក្រទ័ល ដែលមិនមានលំនៅសម្រាប់ជ្រកកោននិងអាហារបរិភោគ។ វត្តព្រះពុទ្ធសាសនាឈ្មោះថាបានជួយសម្រាលភារៈនៃរដ្ឋាភិបាលឱ្យធូរស្រាលបានច្រើនណាស់។

៦–វត្តអារាមគាំទ្រទាំងផ្លូវធម៌ទាំងផ្លូវលោក លោកគ្រូចៅអធិការឬគ្រូសូត្រជាដើមក្នុងវត្តនីមួយៗ ដែលភ្ញាក់ខ្លួនដោយការសិក្សាធម្មវិន័យ បានយល់ផ្លូវសិក្សាតាមសម័យនិយមទៀត។ ការសិក្សាច្បាប់ព្រះពុទ្ធសាសនារបស់បព្វជិតពុទ្ធសាសនិកនោះ ជាកម្លាំងមួយដែលនាំឱ្យមានប្រាជ្ញាស្មារតីបរិបូណ៌ ក្នុងផ្លូវធម៌ផង ផ្លូវលោកផង គឺថាការសិក្សានោះអាចជួយឱ្យមានមធ្យោបាយ ជួយឱ្យមានយោបល់ល្អ ជួយឱ្យមានឧត្តមគតិ មានសមត្ថភាពដល់ខ្លួន ដល់ពួកឧបាសកជើងវត្តដែលជាអ្នកសិក្សា អាចដឹកនាំចិត្តឱ្យមានសទ្ធាជ្រះថ្លាក្នុងការកសាងសេនាសនៈ សម្រាប់បម្រើព្រះពុទ្ធសាសនាផង ចម្រើនដល់ប្រទេសជាតិផង។ ដូចយ៉ាងសាលាសិក្សាអក្សរសាស្ត្រមានសាលាបឋមសិក្សាជាដើម ដែលកើតមានព្រោងព្រាតក្នុងស្រុក-ខេត្តផ្សេងៗ មានខេត្តកណ្ដាល តាកែវ ស្វាយរៀងជាដើម ច្រើនតែកើតអំពីចំហាយនៃការសិក្សាព្រះពុទ្ធសាសនាជាដើម ជាអាទិ៍ គឺថាសាលាសិក្សាទាំងនោះកើតឡើងបានដោយសារស្នាដៃព្រះសង្ឃ មានលោកគ្រូចៅអធិការឬគ្រូសូត្រជាដើម ណែនាំពួកគ្រហស្ថជើងវត្តឱ្យកសាងដោយឥតមើលបំណាំរដ្ឋាភិបាលឡើយ លុះកសាងហើយ ជូនប្រគល់សាលាសិក្សានោះដល់រដ្ឋាភិបាល ដើម្បីឱ្យរាជការចាត់ចែងរកគ្រូបង្រៀនតាមផ្លូវការតទៅ ដែលអាចគាំពាររដ្ឋាភិបាល ជួយកម្លាំងឱ្យរដ្ឋាភិបាលចំណេញថវិកាជាតិបានច្រើនណាស់។

ដំណើរនេះសឱ្យឃើញថា "សាសនាកាលបុគ្គលណាមួយ បានទទួលការអប់រំសិក្សាល្អហើយ អាចនាំឱ្យឆ្ពះឃើញសារប្រយោជន៍ក្នុងផ្លូវធម៌ផង ផ្លូវលោកផង"។ ព្រះពុទ្ធសាសនាឈ្មោះថាជាសាសនាមួយជួយមហាជនប្រទេសកម្ពុជាឱ្យចេះស្រឡាញ់ប្រទេសជាតិរបស់ខ្លួនបានដោយបរិបូណ៌ ជាសាសនាមានទ្រឹស្ដីល្អ អាចជួយសាងសាមគ្គីរបស់ជាតិឱ្យមានវឌ្ឍនធម៌ ឱ្យមានការគោរពជាតិ លើកតម្កើងជាតិ។

៧–វត្តអារាមជាកន្លែងវប្បធម៌ជាតិ អក្សរសាស្ត្ររបស់ជាតិ បើកុំតែបានវត្ត

អារាម ប្រហែលជាសាបសូន្យអស់ទៅហើយ។

ហេតុអ្វីក៏ពោលដូច្នេះ កាលប្រទេសយើងស្ថិតនៅក្រោមអំណាចព្យាបាលបរទេស គេប្រើភាសាខ្មែរគ្រាន់តែបន្តុប់ការប៉ុណ្ណោះ ក្នុងសាលារៀនមានបង្រៀនដែរ តែមានសភាពស្ដួចស្ដើងណាស់ នៅតាមក្រសួងរាជការនានាប្រើសុទ្ធតែភាសាបរទេស លើកលែងតែក្រសួងយុត្តិធម៌ចេញ ជាក្រសួងដែលមានប្រើភាសាខ្មែរដោយភាគច្រើនបន្តិច។ ចុះហេតុអ្វីក៏ភាសាខ្មែរ អក្សរសាស្ត្រខ្មែរ វប្បធម៌ខ្មែរមានអាយុរហូតមកដល់សព្វថ្ងៃនេះ? ព្រោះមានវត្តអារាមជាកន្លែងចិញ្ចឹមទុកឱ្យមានជីវិតរស់នៅ។ កុមារកូនអ្នកស្រុក តែងមកនៅរៀនអក្សរខ្មែរឯវត្តអារាម ឧបាសក ឧបាសិកា ក៏រៀនធម៌ព្រះពុទ្ធសាសនាដែលចារឹកជាអក្សរខ្មែរ នៅវត្តអារាម ភិក្ខុ-សាមណេរសិក្សាធម៌វិន័យព្រះសម្ពុទ្ធព្រមទាំងគម្ពីរតម្រា ក្បួនច្បាប់ផ្សេងៗ ចារឹកជាអក្សរខ្មែរនៅតែក្នុងវត្តអារាម។ ដូច្នេះ វត្តអារាមជាឃ្លាំងអក្សរសាស្ត្រខ្មែរ ដែលទុកជាពន្លឺរស្មីរបស់ជាតិ កាលបើបាត់អក្សរសាស្ត្រ ជាតិក៏អាប់ឱនសាបសូន្យទៅជាលំដាប់។ ដោយហេតុនេះ ពុទ្ធសាសនានៅប្រទេសយើង ឈ្មោះថាជាសាសនាជួយជ្រោមជ្រែងរក្សាទុកនូវវប្បធម៌ អក្សរសាស្ត្រជាតិដោយពិត។

បព្វជិតពុទ្ធសាសនិក ដែលបានរៀនក្នុងផ្លូវគន្ថធុរៈ គឺរៀនគម្ពីរព្រះត្រៃបិដក ចេះចាំយល់ស័ព្ទភាសាបាលី អាចប្រែពីបាលីមកជាភាសាខ្មែរយកសេចក្ដីបានដោយងាយនិងនិពន្ធជាសៀវភៅសិក្សាជាដំបូន្មានអប់រំ ជាកវីនិពន្ធន៍ ជារឿងល្បើកប្រកបដោយគតិវែងខ្លះខ្លីខ្លះ បានបោះពុម្ពផ្សាយជាសៀវភៅធម៌អាថ៌ធំតូចគរគោក សូមអញ្ជើញមើលក្នុងមន្ទីរពុទ្ធសាសនបណ្ឌិត្យ នឹងឃើញសៀវភៅខ្មែរដេរដាសមានព្រះត្រៃបិដកជាដើម ព្រមទាំងបណ្ណា-គារផ្សេងៗ នឹងឃើញសៀវភៅខ្មែរផ្សាយផ្នែកព្រះពុទ្ធសាសនាចេញព្រោងព្រាត ច្រើនតែកើតអំពីស្នាដៃព្រះសង្ឃដែលបានរៀនក្នុងផ្លូវព្រះពុទ្ធសាសនា។ ប្រទេសកម្ពុជា ដែលមានវឌ្ឍនធម៌ចម្រើនរុងរឿងលឺមៗមកនេះ ដោយកម្លាំងរស្មីវប្បធម៌ព្រះពុទ្ធសាសនាជាប្រាកដ។

ស្រាវជ្រាវដោយៈ ជាច់ សុគឹម